**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**
**អគ្គលេខាធិការដ្ឋាន**
លេខ: ០២២ ៧៥ ៧ អ.ក.អ.ច.

# សេចក្តីប្រកាសព័ត៌មាន

## ពិធីប្រកាសផ្សព្វផ្សាយស្តីពី «របាយការណ៍បច្ចុប្បន្នភាពការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ»

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (អ.ក.អ.ច.) មានកិត្តិយសសូមជម្រាបជូនសាធារណជន និងបណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ក្រសួង ស្ថាប័នជាតិ ស្ថានទូត និងអ្នកពាក់ព័ន្ធទាំងអស់ឱ្យបានជ្រាបថា អ.ក.អ.ច. បានរៀបចំពិធីប្រកាសផ្សព្វផ្សាយស្តីពី «របាយការណ៍បច្ចុប្បន្នភាពការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ» នាថ្ងៃចន្ទ ១១រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២១ នៅសាលប្រជុំ ម៉ុក ម៉ារ៉េត ទីស្តីការក្រសួងបរិស្ថាន។

របាយការណ៍បច្ចុប្បន្នភាពនេះ បង្ហាញអំពីការប្តេជ្ញាចិត្ត និងជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីចូលរួមដោះស្រាយការប្រែប្រួលអាកាសធាតុស្របតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីអាកាសធាតុ នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៥ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦។ ក្នុងនោះ ប្រទេសកម្ពុជា និងសហគមន៍អន្តរជាតិបានឯកភាពរក្សាឱ្យបាននូវកំណើនកម្តៅផែនដីឱ្យនៅកម្រិតទាបជាង ២អង្សាសេ និងបន្តឱ្យនៅត្រឹម ១,៥អង្សាសេ បើប្រៀបធៀបទៅនឹងកម្រិតមុនបដិវត្តន៍ឧស្សាហកម្ម ដើម្បីកាត់បន្ថយនូវហានិភ័យ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ របាយការណ៍បច្ចុប្បន្នភាពនេះ បង្ហាញនូវគោលដៅថ្មីច្បាស់លាស់របស់កម្ពុជាពាក់ព័ន្ធនឹងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ឱ្យបានចំនួនប្រមាណ ៦៤,៦លានតោន នៃសមមូលឧស្ម័នកាបូនិកក្នុងមួយឆ្នាំ ត្រឹមឆ្នាំ២០៣០ ឬស្មើនឹង៤១,៧ភាគរយ ដែលក្នុងនោះ ៥៩,១% មកពីវិស័យព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀត។ ជាមួយគ្នានេះដែរ ក្រសួង ស្ថាប័នពាក់ព័ន្ធបានស្នើឡើងនូវសកម្មភាពបន្សាំអាទិភាពរបស់ខ្លួនសរុបមានចំនួន៨៦សកម្មភាព ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឱ្យកាន់តែមានប្រសិទ្ធភាព។

**ឯកឧត្តម វ៉ាន់ មុនីនាថ** អគ្គលេខាធិការ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពបានថ្លែងសុន្ទរកថាស្វាគមន៍នៅក្នុងពិធីផ្សព្វផ្សាយថា ក្នុងនាមជាសមាជិកអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីអាកាសធាតុ (UNFCCC) និងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីអាកាសធាតុ កម្ពុជាបានរៀបចំ និងដាក់ជូនរបាយការណ៍ការចូលរួមចំណែករបស់ជាតិលើកទី១ទៅលេខាធិការដ្ឋានអនុសញ្ញា UNFCCC នៅឆ្នាំ២០១៥ និងដាក់ជូនរបាយការណ៍បច្ចុប្បន្នភាព (Updated NDC) ទៅលេខាធិការដ្ឋានអនុសញ្ញា UNFCCC នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ស្របតាមការប្តេជ្ញាចិត្តរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**



អគារមរតកតេជោ ដីឡូតិ៍លេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ (៨៥៥) ៨៩ ២១៨ ៣៧០

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងក្នុងកិច្ចប្រជុំកំពូលស្តីពីអាកាសធាតុកាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២០។

**ឯកឧត្តម** Björn Häggmark ឯកអគ្គរាជទូត ព្រះរាជាណាចក្រស៊ុយអែត ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាបានបង្ហាញចំណាប់អារម្មណ៍ និងវាយតម្លៃខ្ពស់ចំពោះរបាយការណ៍បច្ចុប្បន្នភាពនេះក្នុងការចូលរួមចំណែកកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការកសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ **ឯកឧត្តម** បានអបអរសាទរចំពោះក្រសួងបរិស្ថានក្នុងការរៀបចំរបាយការណ៍បច្ចុប្បន្នភាពនេះប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងច្បាស់លាស់ហើយប្រទេសស៊ុយអែតបានគាំទ្រក្នុងដំណើរការរៀបចំរបាយការណ៍នេះតាមរយៈកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។ **ឯកឧត្តម**ក៏បានលើកឡើងថា របាយការណ៍បច្ចុប្បន្នភាពនេះមិនគ្រាន់តែបង្ហាញពីការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជាក្នុងការចូលរួមកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់តែប៉ុណ្ណោះទេ តែរបាយការណ៍នេះថែមទាំងចូលរួមកាត់បន្ថយភាពងាយរងគ្រោះបណ្តាលមកពីការប្រែប្រួលអាកាសធាតុ លើកកម្ពស់សមភាពយេនឌ័រ និងធ្វើឱ្យប្រសើរឡើងនូវយុត្តិធម៌អាកាសធាតុ។

**ឯកឧត្តម សាយ សំអាល់** ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងជារដ្ឋមន្ត្រីក្រសួងបរិស្ថានបានគូសបញ្ជាក់ផងដែរថា ប្រទេសកម្ពុជាបានដើរតួនាទីជាប្រទេសមួយដែលមានជំហរគាំទ្រដ៏រឹងមាំចំពោះសកម្មភាពពហុភាគី ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្នុងនាមជាប្រទេសមួយដែលងាយរងគ្រោះពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលបានយល់ពីភាពបន្ទាន់ដែលតម្រូវឱ្យចាត់វិធានការដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុប្រកបដោយមហិច្ឆតា ស្របទៅតាម «**ការទទួលខុសត្រូវរួម តែកម្រិតផ្សេងគ្នាទៅតាមសមត្ថភាពរៀងៗខ្លួន**» ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ **ឯកឧត្តម** បានបន្ថែមទៀតថា របាយការណ៍ Updated NDC របស់ប្រទេសកម្ពុជាបានបង្ហាញពីការប្តេជ្ញាចិត្ត និងតម្រូវការសម្រាប់ទសវត្សរ៍បន្ទាប់ ដើម្បីធ្វើឱ្យសម្រេចបាននូវចក្ខុវិស័យនៃសង្គមមួយដែលមានការបញ្ចេញកាបូនតិច មានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយចីរភាព។

ពិធីប្រកាសផ្សព្វផ្សាយនេះ មានការអញ្ជើញចូលរួមតំណាងពីព្រឹទ្ធសភាព រដ្ឋសភា ក្រសួង ស្ថាប័នពាក់ព័ន្ធសំខាន់ៗ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល អ្នកសារព័ត៌មាន និងវិស័យឯកជន។ របាយការណ៍នេះ ត្រូវបានរៀបចំឡើងដោយមានការគាំទ្រពីក្រសួង ស្ថាប័នជាតិ និងដៃគូនានារួមមាន៖ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (ដោយមានការគាំទ្រថវិកាពីសហភាពអឺរ៉ុប ប្រទេសស៊ុយអែត និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ) ធនាគារពិភពលោក វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល អង្គការស្បៀងអាហារនិងកសិកម្ម និងដៃគូនានា។ របាយការណ៍លម្អិត មាននៅក្នុងគេហទំព័រខាងក្រោម៖

https://ncsd.moe.gov.kh/resources/document/Cambodia_Updated_NDC។

ថ្ងៃសុក្រ១២រោចខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៩ខែកុម្ភៈឆ្នាំ២០២១


***ព័ត៌មានបន្ថែម សូមទាក់ទង :***

នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

ទូរស័ព្ទ ៖ (855) 78 996 479

អ៊ីម៉ែល ៖ maohakccd.se@gmail.com

គេហទំព័រ ៖ https://ncsd.moe.gov.kh